# ប្រជល់ក្នុងចម្លាក់បុរាណខ្មែរ

ជាការពិតណាស់ មនុស្សនៅលើពិភពលោកគ្រប់ទីកន្លែងតែងមានការកំសាន្ត ដោយល្បែងផ្សេងៗ ទាំងល្បែងបង្កើតដោយការធ្វើដោយឧបករណ៍ និងល្បែងដែលយកសត្វផ្សេងៗមកប្រជល់យកឈ្នះ និងចាញ់។ យ៉ាងណាមិញ ក្នុងសង្គមខ្មែរនាសម័យបុរាណក៏យ៉ាងដូច្នោះដែរ។ តាមចម្លាក់ក្រឡោតទាបនៅលើជញ្ជាំងប្រាសាទមួយចំនួនពិសេសប្រាសាទបាភួន អង្គរវត្ត និងបាយ័ន្តបង្ហាញឱ្យយើងដឹងអំពីល្បែងប្រជាប្រិយមួយចំនួនដែលខ្មែរនាសម័យបុរាណបានលេងជាការកំសាន្ត និងអាចភ្នាល់ជាប្រាក់។

## តើល្បែងប្រជល់ទាំងនោះមានអ្វីខ្លះ?

យើងពុំមានឯកសារជាសិលាចារឹកណាមួយនិយាយឱ្យលម្អិតអំពីល្បែង និងលក្ខន្តិកក្នុងការលេងនោះទេ ពោលគឺយើងអាចដឹងថា មានល្បែងទាំងនោះតាមរយៈចម្លាក់ក្រឡោតទាបនៅតាមប្រាសាទប៉ុណ្ណោះ។ ល្បែងទាំងនោះមានដូចជា៖

### ក.ប្រជល់មាន់

ការប្រជល់មាន់អាចជាល្បែងដែលមានការពេញនិយមជាងគេក្នុងសង្គមខ្មែរ ដ្បិតល្បែងនេះត្រូវបានឆ្លាក់បង្ហាញជាលើកដំបូងនៅលើជញ្ជាំងប្រាសាទអង្គរវត្ត ដែលជាប្រាសាទយ៉ាងសំខាន់សម្រាប់ព្រះរាជាក្រោយចូលទីវង្គត់ គឺព្រះបាទសូរ្យវរ្ម័នទី២ (គ.ស ១១១៣ដល់១១៥០)។ ចម្លាក់នេះត្រូវបានឆ្លាក់នៅលើជញ្ជាំងខាងត្បូងនៃជ្រុងឥសាន្តនៃប្រាង្គជ្រុងនិរតីរបស់ថែវទី១ (រូបលេខ១) ជាចម្លាក់បង្ហាញពីវង្សត្រកូលអភិជនជាតិចិនដែលអាចមានភរិយាជាប់ខ្សែស្រឡាយនិងក្សត្រ ស៊ីផឹកនៅលើទូក លេងអុក និងលេងជល់មាន់ទៀតផង។ ចម្លាក់នេះបង្ហាញថា មនុស្សទាំងនោះទាំងជនជាតិខ្មែរ និងចិនមានទឹកមុខសប្បាយរីករាយយ៉ាងខ្លាំងក្នុងការលេងល្បែងជល់មានរបស់ពួកគេ។ មានមនុស្ស២នាក់កាន់មាន់ដាក់ផ្ទល់គ្នា និងមនុស្ស២នាក់ទៀតនៅខាងលើកន្ទៀតមាន់ម្នាក់មួយបង្អួតគ្នាហើយលាដៃត្រង់ ហាក់បីដូចជាការទទួលឬភ្នាល់ជាប្រាក់។ ចម្លាក់បែបនេះមានបង្ហាញម្តងទៀតនៅលើជញ្ជាំងស្ពាបខាងកើត នៃថែវខាងត្បូងរបស់ប្រាសាទបាយ័ន្ត (រូបលេខ២)។ ចម្លាក់នៅទីនេះពុំសូវមានភាពរស់រវើកដូចនៅប្រាសាទអង្គរវត្តទេ តែគេបង្ហាញយ៉ាងច្បាស់ពីមនុស្ស២ក្រុម គឺម្ខាងជាជនជាតិខ្មែរ (ខាងឆ្វេងឬលិច) និងម្ខាងទៀតជាជនជាតិ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ចិន (ស្តាំឬកើត) កាន់មាន់ម្នាក់១ ផ្ទុលគ្នា។ មនុស្សម្នាក់ក្នុងក្រុមកាន់មាន់ជន្ទរគ្នា រីឯអ្នកដទៃគឺមានកាយវិការដដែក តថ្លៃគ្នាក្នុងការភ្នាល់យ៉ាងសកម្ម។ នេះបញ្ជាក់ថា ល្បែងប្រជល់មាន់គឺអាចជាល្បែងដែលមានប្រជាប្រិយភាព និងពេញនិយមខ្លាំងរបស់មនុស្សក្នុងសង្គមខ្មែរនាសម័យនោះ។

**ខ.ប្រជល់ជ្រូក (ព្រៃ)**

ល្បែងប្រជល់ជ្រូកពុំមានក្នុងសង្គមខ្មែរសព្វថ្ងៃទៀតទេ។ នៅសម័យបុរាណ ល្បែងប្រជល់ជ្រូកអាចជាល្បែងដែលមានប្រជាប្រិយភាពដូចនិងការប្រជល់មាន់ផងដែរ។ ចម្លាក់ប្រជល់ជ្រូកដែលបង្ហាញជាលើកដំបូង គឺនៅតាមជញ្ជាំងប្រាសាទបាភួន ជាចម្លាក់ក្នុងក្បាច់អង្កត់ការតូចៗ (រូបលេខ៣) ដោយពុំមានបង្ហាញពីតួអង្គមនុស្សដែលចូលរួមក្នុងការជល់នោះទេ។ ចម្លាក់ទាំងនេះមានលក្ខណៈ និងទិដ្ឋភាពជាប់ទាក់ទងនឹងទេវកថាខ្លះ ជាជីវភាពធម្មតាខ្លះ ដែលយើងអាចឃើញនៅតាមជញ្ជាំងថែវដែលធ្លាក់ជុំវិញប្រាសាទនោះ។ ចម្លាក់នៅប្រាសាទបាយ័ន្តបង្ហាញយ៉ាងច្បាស់អំពីការប្រជល់ជ្រូក (រូបលេខ២៤) គឺមានមនុស្ស២នាក់កាន់ខ្សែចងជ្រូកម្នាក់១ មកដាក់ផ្ទុលទល់មុខនឹងគ្នា។ មនុស្សផ្សេងៗដែលនៅពីក្រោយមានកាយវិការតវ៉ា លើកដៃ ប្រហែលជដែករឿងភ្នាល់ជាប្រាក់។

**គ.ប្រជល់ត្រីក្រឹម**

នៅលើជញ្ជាំងស្លាបខាងលិចនៃថែវខាងត្បូងរបស់ប្រាសាទបាយ័ន្ត មានចម្លាក់បង្ហាញពីមនុស្សមួយក្រុមអង្គុយជុំវិញពាងមួយ ដោយម្នាក់ៗបើកភ្នែកសំលឹងទៅក្នុងពាងនោះ (រូបលេខ២៥)។ មនុស្ស២នាក់លូកដៃទៅក្នុងពាង ហាក់បីដូចជាសកម្មភាពចាប់អ្វីនៅក្នុងនោះ។ ចំណែកមនុស្ស២នាក់នៅខាងក្រោយ (ពីលើ) មានកាន់វត្ថុម្នាក់មួយនៅដៃម្ខាង ហើយងើយសំលឹងទៅវត្ថុនោះ គឺប្រៀបដូចជាការមើលត្រីក្នុងដបដែរ។ ចំនុចនេះ វាមានលក្ខណៈដូចគ្នាទៅនឹងការប្រជល់ត្រីក្រឹមក្នុងសង្គមខ្មែរជាង៣០ឆ្នាំមុន ដែលជាទូទៅគេដាក់ត្រីក្នុងពាងតូចល្មមឱ្យជល់គ្នា ហើយមើលពីលើ។ បើយើងប្រៀបធៀបមកសព្វថ្ងៃ គឺមានទិដ្ឋភាពខុសបន្តិច ត្រង់ថា គេតែងដាក់ត្រីឱ្យជល់គ្នានៅក្នុងកែវថ្លា ហើយមើលពីចំហៀង (ដោយមានច្បាប់ហាមមើលពីលើ ព្រោះខ្លាចត្រីផ្អើល)។

**ឃ.ប្រជល់ពពែ**

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

បច្ចុប្បន្ន ល្បែងប្រជល់ពពែនៅមានតាមបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ីខាងលិច ឥណ្ឌា និងអារ៉ាប់ជាដើម។ ក្នុងសង្គមខ្មែរសម័យបុរាណ សត្វពពែអាចជាប្រភេទសត្វដែលគេចិញ្ចឹមសម្រាប់យកសាច់ជាសំខាន់ ព្រោះវាផ្តល់នូវថាមពលជាងសាច់សត្វដទៃ ហើយយើងឃើញមានវត្តមានពាក្យពពែក្នុងសិលាចារឹក តាំងពីសតវត្សទី៧មកម៉្លេះ ឧទាហរណ៍ ដូចជាសិលាចារឹក K.600[១] និយាយអំពីអំណោយដល់ទីប្រាសាទ និងទេពក្នុងនោះមានសត្វពពែចំនួន១០ក្បាលផងដែរ។ ចម្លាក់បង្ហាញពីការប្រជល់សត្វពពែនេះគឺមានតែតាមជញ្ជាំងថែវរបស់ប្រាសាទបាពួន ជាចម្លាក់តូចៗក្នុងការេ (រូបលេខ២៦)។

## ង.ប្រជល់សេះ

យើងពុំមានភស្តុតាងបង្ហាញអំពីការប្រជល់សេះតាមរយៈសិលាចារឹកទេ។ ចម្លាក់ប្រជល់សេះមានបង្ហាញនៅតាមជញ្ជាំងថែវរបស់ប្រាសាទបាពួនដែរ (រូបលេខ២៧)។ សេះជាសត្វមួយដែលកម្រនិងជល់ឬខាំគ្នាណាស់។ ក្នុងពេលបច្ចុប្បន្ននេះប្រសិនបើគេចង់ឱ្យសេះឈ្លោលខាំ ឬប្រយុទ្ធគ្នា គឺគេតែងយកសេះញីមួយមកធ្វើជាផ្ទាក់ ឱ្យសេះឈ្មោលដណ្តើមគ្នា ប្រយុទ្ធគ្នារហូតដល់មានអ្នកចាញ់ ហើយរត់ចេញទៅ។

## ច.ប្រជល់គោ

ពាក្យ *គោ* ជាភាសាសំស្ក្រឹត រីឯពាក្យខ្មែរដែលមានប្រើនៅសម័យបុរាណ គេតែងប្រើពាក្យ *ត្មុរ*។[២] ការប្រជល់គោអាចជាល្បែងដែលមានប្រជាប្រិយភាពដែរក្នុងសម័យបុរាណ ហើយរហូតមកដល់សព្វថ្ងៃ ក៏នៅមានតំបន់ខ្លះនៅថែរក្សាការលេងល្បែងនេះ។ ល្បែងប្រជល់គោនៅតែមានប្រជាប្រិយភាពនៅឥណ្ឌា និងសៀម។ ចម្លាក់ប្រជល់សត្វគោមានបង្ហាញនៅលើជញ្ជាំងប្រាសាទបាពួនដែរ (រូបលេខ២៨)។

## ឆ.ប្រជល់ដំរី

ដំរីជាសត្វដែលមានតួនាទីសំខាន់ក្នុងសង្គមខ្មែរ នាសម័យបុរាណ ដែលគេបានចាប់និងផ្សាំងសម្រាប់បំរើដល់ការងារទូទៅប្រចាំថ្ងៃ និងពិសេស គឺចូលរួមក្នុងចម្បាំង។[៣] នា

[១] G. Cœdès 1942:21

[២] Savaros Pou 1992:226

[៣] សុខ កែវ សុវណ្ណារ៉ា ២០២០:១

សម័យបុរាណ ដំរីត្រូវបានគេហ្វឹកហ្វឺនឱ្យមានការប្រយុទ្ធគ្នារវាងដំរី និងដំរី ដើម្បីជាបទពិសោធន៍ប្រយុទ្ធជាមួយដំរីសត្រូវ។ ទំនៀមបែបនេះ មាននៅតែបន្តធ្វើនៅស្រុកសៀមនៅឡើយ។ ចំពោះចម្លាក់ប្រជល់ដំរីមានបង្ហាញនៅតាមជញ្ជាំងថែវប្រាសាទបាពួន (រូបលេខ៩)។

## ជ.ប្រជល់គុជសិង្ហ

គុជសិង្ហមានន័យថា តោមានប្រមោយដំរី។ នេះជាប្រភេទសត្វក្នុងទេវកថា ដែលមិនមានពិតនៅក្នុងធម្មជាតិនេះទេ។ ជាការកែច្នៃ គេបានឆ្លាក់ចម្លាក់ប្រយុទ្ធគ្នារវាងគុជសិង្ហនៅលើជញ្ជាំងថែវប្រាសាទបាពួនដូចម្លាក់ប្រជល់សត្វដទៃដែរ (រូបលេខ១០)។

## ឈ.ប្រជល់ក្របី

សិលាចារឹកមួយ K.91[៦] ក្នុងសតវត្សទី១១ និយាយអំពីគ្រួសារមន្ត្រីបំរើដល់ក្សត្រជាច្រើនជំនាន់ ហើយក្នុងជំនាន់ក្សត្រឈ្មោះ **វ្រះ បាទ បរមវីរលោក** (ជ័យវរ្ម័នទី៥ គ.ស៩៦៨ ដល់១០០០) ស្តេចបានបង្គាប់ឱ្យមន្ត្រីម្នាក់ផ្តលក្របី ហើយក្របីបានឈ្នះលេខ១ ( **វ្រះ បាទ បរមវីរលោក ប្រេ អោយ ផ្តុល ក្របិ ជ្នះ កាប មួយ តោង តាច ចុញ**....) ស្តេចបានតែងតាំងឱ្យមានតំណែង និងងារជា **វ្រះ កម្រតេង អញ ឝ្រី វីរបរាក្រម**។ ក្រៅពីសិលាចារឹកនេះ យើងពុំមានភស្តុតាងណាបង្ហាញពីល្បែងប្រជល់ក្របីជាចម្លាក់ ដូចការប្រជល់សត្វដទៃទេ។

ទាំងនេះ គឺជាការបង្ហាញដោយត្រួសៗអំពីចម្លាក់ទាក់ទងនិងការប្រជល់សត្វដែលមាននៅក្នុងសង្គមខ្មែរសម័យបុរាណ។ យើងពុំមានឯកសារឬភស្តុតាងជាសិលាចារឹកដែលរៀបរាប់លម្អិតអំពីសម្មភាពទាំងនេះទេ។ នេះជាចំនុចពិបាកក្នុងការបកស្រាយពន្យ ល់អំពីល្បែងប្រជល់ទាំងនេះឱ្យបានល្អិតល្អន់ណាស់។

# ឯកសារយោង


សុខ កែវ សុវណ្ណារ៉ា

២០១២), *ដំរីក្នុងវិស័យសិល្បៈខ្មែរ*, ក្នុង AMS, ភ្នំពេញ។

G. Cœdès,

1942, *Inscription du Cambodge*, Volume II, Hanoi.

Savaros Pou,

1992, *An Old Khmer-French-English Dictionary*, Cedoreck, Paris.


[៦] G. Cœdès 1942:129



រូបលេខ១១៖ ចម្លាក់ជល់មាន់នៅប្រាសាទអង្គរវត្ត



រូបលេខ១២៖ ចម្លាក់ជល់មាន់នៅប្រាសាទបាយ័ន្ត

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៣៖ ចម្លាក់ជល់ជ្រូកនៅ



រូបលេខ២៤៖ ចម្លាក់ជល់ជ្រូកនៅ



រូបលេខ២៥៖ ចម្លាក់ជល់ត្រីក្រឹមនៅ



រូបលេខ២៦៖ ចម្លាក់ជល់ពពែនៅ



រូបលេខ២៧៖ ចម្លាក់ជល់សេះនៅ



រូបលេខ២៨៖ ចម្លាក់ជល់គោនៅ



រូបលេខ២៩៖ ចម្លាក់ដំរីជ្រូកនៅប្រាសាទ



រូបលេខ២១០៖ ចម្លាក់ជល់គជសិង្ហនៅ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា